វិទ្យាស្ថានបណ្តុះបណ្តាល និង
ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

សាកលវិទ្យាល័យស៊ីដនី

# ឥទ្ធិពលប្រព័ន្ធធារាសាស្រ្ត ទៅលើទ្រព្យសម្បត្តិគ្រួសារ




គុង គីមស៊ុន  ហែម សុចិត្ត និង Paulo SANTOS

ឯកសារពិភាក្សាលេខ ៥៧

កក្កដា ២០១២

ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

ម.ព.ឯ.ក AIDOC
Code: 158-024
Date:
Donated by:

# ឥទ្ធិពលប្រព័ន្ធធារាសាស្ត្រទៅលើ ទ្រព្យសម្បត្តិគ្រួសារ

## ឯកសារពិភាក្សាលេខ ៥៧

គុង គឹមស៊ុន ហែម សុចិត្ត និង Paulo SANTOS

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ខែកក្កដា ២០១២ ភ្នំពេញ កម្ពុជា

**បេសកកម្ម វបសអ**

ក្នុងលក្ខណៈជា វិទ្យាស្ថានកម្ពុជាឯករាជ្យផ្នែកស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្ម រួមចំណែកដល់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព។

វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា។

**© រក្សាសិទ្ធិឆ្នាំ២០១២ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)**

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃឯកសារនេះដែលអាចយកទៅចម្លងទុកឬផ្សព្វផ្សាយតាមទម្រង់និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង...។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី វបសអ ។

ISBN-10: 99950–52–50-8

**ឥទ្ធិពលប្រព័ន្ធធារាសាស្ត្រទៅលើទ្រព្យសម្បត្តិគ្រួសារ**
**The Impact of Irrigation on Household Assets**

**តុង គឹមស៊ុន** អ្នកស្រាវជ្រាវ និងជាអ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI
**ហែម សុចិត្ត** អ្នកស្រាវជ្រាវ កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI
Paulo SANTOS មហាវិទ្យាល័យកសិកម្ម អាហារ និងធនធានធម្មជាតិ នៃសាកលវិទ្យាល័យស៊ីដនី

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់ វបសអ ទេ។*

**វិទ្យាស្ថាន** CDRI

អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ុំ-ចាន់ថា និង យូ-សិទ្ធីរិទ្ធ
បកប្រែដោយ៖ ខេង សេង
បោះពុម្ពនៅប្រទេសកម្ពុជាដោយ រោងពុម្ពអង្គរអុហ្វសិត រាជធានីភ្នំពេញ

# មាតិកា


បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ ........ v
សេចក្តីថ្លែងអំណរគុណ ........ vii
សម្រង់អត្ថបទ ........ 1

១. សេចក្តីផ្តើម ........ 3
២. ការសិក្សាឯកសារមានស្រាប់ ........ 5
៣. ប្រភពទិន្នន័យ ........ 7
៤. វិធីសាស្ត្រគណនាជាក់ស្តែង និងការប៉ាន់ស្មាន ........ 9

៤.១ គំរូសេដ្ឋមាត្រសាស្ត្រ ........ 9
៤.២ ការវាយតម្លៃសំអាងលើការពិសោធន៍ ........ 10

៥. សេចក្តីសន្និដ្ឋាន ........ 15
ឯកសារយោង ........ 16
ឧបសម្ព័ន្ធ ........ 18
បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI ........ 20


## បញ្ជីរូបភាព និងតារាង


រូបភាព ១៖ បម្រែបម្រួលទ្រព្យសម្បត្តិក្នុងគ្រួសារ (២០០៨-២០១០) ........ 11

តារាង១៖ ស្ថិតិបែបពណ៌នារបស់អថេរចំណុះគេ និងអថេរឯករាជ្យ ........ 10
តារាង ២៖ ទ្រព្យសម្បត្តិក្នុងគ្រួសារ តាមស្ថានភាពស្រោចស្រព ........ 12
តារាង ៣៖ កត្តាកំណត់ទ្រព្យសម្បត្តិគ្រួសារក្នុងឆ្នាំ២០១០ (OLS) ........ 13
តារាង ៤៖ កត្តាកំណត់ទ្រព្យសម្បត្តិគ្រួសារក្នុងឆ្នាំ២០១០ (TSLS) ........ 14
តារាង ៥៖ កត្តាកំណត់ទ្រព្យសម្បត្តិគ្រួសារក្នុងឆ្នាំ២០១០ (LIML) ........ 14


## ឧបសម្ព័ន្ធ


តារាង A1៖ កត្តាកំណត់នៃលទ្ធភាពទទួលបានការស្រោចស្រព (OLS) ........ 18
តារាង A2៖ ផ្ទៃដីប្រមូលផល និង ផ្ទៃដីដាំដុះស្រូវសរុប ........ 19

# បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| ផសស | ផលិតផលក្នុងស្រុកសរុប ( Gross Domestic Product: GDP ) |
| សកបទ | សហគមន៍កសិករប្រើប្រាស់ទឹក ( Farmer Water User Community: FWUC ) |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី ( Asian Development Bank ) |
| ANOVA | ការវិភាគវ៉ារីយ៉ង់ ( Analysis of Variance ) |
| AusAID | ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ ( Australia Aid for International Development ) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ( Cambodia Development Resource Institute ) |
| FGD | ការពិភាក្សាតាមក្រុមស្នូល ( Focus Group Discussion ) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ ( International Monetary Fund ) |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ( Japan International Cooperation Agency ) |
| LIML | វិធីសាស្ត្រ Limit-information Maximum Likelihood |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ( Ministry of Agriculture, Forestry and Fisheries ) |
| MEF | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ( Ministry of Economy and Finance ) |
| MOWRAM | ក្រសួងធនធានទឹក និង ឧតុនិយម ( Ministry of Water Resources and Meteorology ) |
| NGO | អង្គការមិនមែនរដ្ឋាភិបាល ( Non-governmental Organisation ) |
| NIS | វិទ្យាស្ថានជាតិស្ថិតិ ( National Institute of Statistics ) |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ( National Strategic Development Plan ) |
| OLS | វិធីសាស្ត្រ Ordinary Least Squares |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ( Royal University of Phnom Penh ) |
| TSLS | វិធីសាស្ត្រ Two-stage Least Squares |
| USDA | ក្រសួងកសិកម្មសហរដ្ឋអាមេរិក ( United States Department of Agriculture ) |
| USYD | សាកលវិទ្យាល័យស៊ីដនី ( University of Sydney ) |
| WB | ធនាគារពិភពលោក ( World Bank ) |
| WRMRCDP | កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក ( Water Resource Management Research Capacity Development Programme ) |

# សេចក្ដីថ្លែងអំណរគុណ

ឯកសារនេះជាលទ្ធផលនៃគម្រោងស្រាវជ្រាវរួមគ្នាមួយរវាង វិទ្យាស្ថានបណ្តុះបណ្តាលស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ-CDRI) និង សាកលវិទ្យាល័យស៊ីដនី (USYD) បានអនុវត្តចប់សព្វគ្រប់ដោយមានការជួយគាំទ្រ និងកិច្ចសហប្រតិបត្តិការពីសំណាក់បុគ្គលជាច្រើន។

យើងខ្ញុំសូមសម្តែងការដឹងគុណដល់ AusAID ចំពោះជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុដល់កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក (WRMRCDP) ដែលជាកម្មវិធីស្រាវជ្រាវរយៈពេលប្រាំឆ្នាំរួមគ្នា រវាងវិទ្យាស្ថាន CDRI សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) និងសាកលវិទ្យាល័យស៊ីដនី (USYD) ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយ ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសផងដែរដល់បណ្ឌិត ស៊ិន សុវិទ្ធ និងលោកJohnDoreដែលជាបុគ្គលិកគម្រោងរបស់ AusAID។

យើងខ្ញុំសូមអរគុណដល់ លោក យ៉ែម ដារារដ្ឋ លោក រស់ បានសុខ អ្នកស្រី សំ ស្រីមុំ លោក ខោល ម៉ានី និងលោក នង គាមនី ដែលបានចូលរួមពីដំបូងក្នុងការរចនារៀបចំការស្រាវជ្រាវ ការគ្រប់គ្រង ការចុះសិក្សាដល់កន្លែង និងការបញ្ចូលទិន្នន័យ។ យើងខ្ញុំក៏សូមអរគុណដល់ អ្នកស្រី ប៊ុន ដូរីណា និង លោក កែវ បុប្ផា ដែលបានផ្តល់សេវាជំនួយការយ៉ាងល្អដល់ការស្រាវជ្រាវ។ ការសិក្សានេះបានទទួលការជ្រោមជ្រែងដើម្បីស្ថាបនា និងផ្តល់មតិណែនាំដ៏មានតម្លៃពី លោក គឹម សួ លោក ចែម ផល្លា សាស្ត្រាចារ្យ Philip Hirsch ព្រមទាំងមតិត្រឡប់ដ៏មានប្រយោជន៍ ពីសំណាក់អាជ្ញាធរស្រុក សមាជិកក្រុមប្រឹក្សាឃុំ និងសមាជិកសហគមន៍កសិករអ្នកប្រើប្រាស់ទឹក (សកបទ) ក្នុងខេត្តកំពង់ឆ្នាំង កំពង់ធំ និង ពោធិ៍សាត់។ យើងខ្ញុំសូមអរគុណផងដែរដល់ លោក Larry Strange បណ្ឌិត Hossein Jalilian និងលោក អ៊ឹង ស៊ានលី ដែលបានគាំទ្រ និងលើកទឹកចិត្តដល់ការសិក្សានេះ។

យើងខ្ញុំសូមអរគុណជាពិសេសដល់មេភូមិនានា និងសហការី ដែលបានជួយសម្របសម្រួលដល់ការស្រាវជ្រាវនេះ និងសូមអរគុណដល់គ្រួសារគោលដៅនៃការសិក្សាដែលបានចំណាយពេលដ៏មានតម្លៃចូលរួមក្នុងការស្រាវជ្រាវ។ ឯកសារនេះមិនអាចសម្រេចបានទេ ប្រសិនបើមិនមានកិច្ចសហប្រតិបត្តិការ និងការគាំទ្រដ៏សម្បូរសរបស់លោកអ្នកទាំងនោះ។

## សង្ខេបអត្ថបទ

អត្ថបទនេះផ្អែកលើ ទិន្នន័យប្រមូលបានពីអង្កេតឆ្នាំ២០០៨-២០១០ លើ ២២០គ្រួសារជ្រើសរើស និងមានបំណងបង្ហាញពីទំនាក់ទំនងរវាងប្រព័ន្ធធារាសាស្ត្រ និងទ្រព្យសម្បត្តិគ្រួសារប្រើយូរឆ្នាំ ដូចជា សត្វចិញ្ចឹម បរិក្ខារកសិកម្ម គោក្របី និងសត្វអូសទាញ។ លទ្ធផលបានបង្ហាញថា ប្រព័ន្ធ ធារាសាស្ត្រមិនទំនងជះឥទ្ធិពលវិជ្ជមានទៅលើ ចំនួនទ្រព្យប្រើយូរឆ្នាំ សត្វចិញ្ចឹម បរិក្ខារកសិកម្ម គោក្របី និងសត្វអូសទាញ នោះទេ។ ផ្ទុយទៅវិញមូលធនមនុស្សបានដើរតួនាទីសំខាន់ណាស់ ក្នុងការបង្កើនទ្រព្យប្រើយូរឆ្នាំ។ លទ្ធផលទាំងនេះអាចឆ្លុះបញ្ចាំងពីធាតុពិតដែល ប្រព័ន្ធធារាសាស្ត្រនៅកម្ពុជា ដំណើរការមិនបានល្អគ្រប់គ្រាន់ ដើម្បីអាចជះឥទ្ធិពលគួរឲ្យកត់សំគាល់ដល់ការបង្កើនទ្រព្យសម្បត្តិគ្រួសារ។ ក្នុងស្ថានភាពបែបនេះ ការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ គួរផ្តោតកាន់តែច្រើនលើការសម្រេចបានតុល្យភាពល្អរវាងការពង្រីកប្រព័ន្ធធារាសាស្ត្រ និងការកែលំអប្រសិទ្ធភាពប្រព័ន្ធធារាសាស្ត្រ ពោលគឺ ការមានទឹកស្រោចស្រពទាំងរដូវវស្សា និងរដូវប្រាំង ការកំណត់កម្ពស់ទឹកសមស្របសម្រាប់ការស្រោចស្រពប្រកបដោយប្រសិទ្ធភាព និងការធានាឲ្យមានការគ្រប់គ្រងទឹកប្រកបដោយសមធម៌ទូទាំងតំបន់។ លទ្ធផលស្រាវជ្រាវ ក៏បានគាំទ្រដល់ទស្សនៈជាទូទៅថា កំណើនវិនិយោគលើមូលធនមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ អាចមានឥទ្ធិពលទៅលើចំនួនទ្រព្យសម្បត្តិគ្រួសារ ខ្លាំងជាង វិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតែមួយមុខ។

# ១ សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ថា ត្រូវតែធ្វើយ៉ាងណាឲ្យហេដ្ឋារចនាសម្ព័ន្ធរូបវន្តមានដំណើរការល្អ ដើម្បីអាចសម្រេចបាន ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព កំណើន និងការកាត់បន្ថយភាពក្រីក្រ។ ដោយសារហេតុផលនេះ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ បានកំណត់ ការស្តារឡើងវិញ និងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាសមាសភាគដ៏សំខាន់បំផុតមួយ ដែលមានបួនអនុសមាសភាគ៖ (១) ការស្តារឡើងវិញ និងស្ថាបនាបណ្តាញដឹកជញ្ជូន (២) ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ (៣) ការអភិវឌ្ឍវិស័យថាមពល (រួមមាន ប្រេង និងឧស្ម័ន) និងបណ្តាញអគ្គិសនី និង (៤) ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (RGC 2009)។

ក្នុងឆ្នាំ២០០៦-២០០៨ ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) បានអនុវត្តការងារ គួរកត់សម្គាល់ក្នុងការស្តារ រក្សា និងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ តាមរយៈការអភិវឌ្ឍគម្រោងប្រព័ន្ធធារាសាស្ត្រចំនួន ១៤៤ ដែលមានសមត្ថភាពផ្តល់ការស្រោចស្រពដល់ផ្ទៃដី ២៦៧.២២៤ហិកតា (RGC 2009)។ នៅចុងឆ្នាំ២០០៨ ដីស្រោចស្រព មាន ៨២៧.៣៧៣ហិកតា ស្មើនឹង ៣១,៦% នៃផ្ទៃដីដាំដុះសរុប (២.៦១៥.៧១៤ហិកតា) (RGC 2009)[1]។ ដោយគិតដល់ពេលអនាគត រាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាពលើការស្តារ ថែទាំ ស្ថាបនា និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដើម្បីជម្រុញផលិតកម្មកសិកម្ម។ ក្នុងបំណងបង្កើនប្រសិទ្ធភាពការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ រាជរដ្ឋាភិបាលបានដាក់បញ្ចូល គោលគំនិតនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួម (PIMD) ទៅក្នុងគោលនយោបាយវិស័យទឹក និងបានបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក (សកបទ/FWUC)។

មានការកត់សម្គាល់ជាទូទៅថា ប្រព័ន្ធធារាសាស្ត្រផ្តល់អត្ថប្រយោជន៍ជាច្រើន ដែលអាចរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច (Dillon 2011; Hussain 2007a; Hussain 2007b; Hussain & Hanjra 2004)។ Hussain and Hanjra (2004) បានពិពណ៌នាពីចំណុចសំខាន់ៗបី ដើម្បីអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ៖

- មីក្រូ៖ តាមរយៈការបង្កើនផលចំណូលអំពី មូលធនរូបវន្ត មូលធនមនុស្ស និងមូលធនសង្គម របស់គ្រួសារក្រីក្រ (ផលិតភាព)។
- កម្រិតកណ្តាល៖ តាមរយៈការធ្វើសមាហរណកម្ម ជនក្រីក្រទៅក្នុងទីផ្សារខាងផលិតផល និងចំណេះដឹង (ការចូលរួមក្នុងទីផ្សារ)។
- ម៉ាក្រូ៖ តាមរយៈការកែលំអអត្រាកំណើនរបស់ជាតិ និងបង្កើតនូវកត្តាខាងក្រៅវិជ្ជមានជំនាន់ទី ២ (កំណើនសេដ្ឋកិច្ច)។

---

[1] MOWRAM បានឲ្យដឹងថា ផ្ទៃដី ១.១២០.២៤៦ហិកតា ស្មើនឹង ៤៣% នៃផ្ទៃដីដាំដុះសរុប បានទទួលការស្រោចស្រព (CDRI ២០១០)។ ដោយសារមិនមានទិន្នន័យគ្រប់គ្រាន់អំពីផ្ទៃដីស្រោចស្រពពីមួយឆ្នាំទៅមួយឆ្នាំ គេមានការលំបាកជាខ្លាំង ក្នុងការវាយតម្លៃពីល្បឿននៃការពង្រីកប្រព័ន្ធធារាសាស្ត្រ។ FAO (2005) បានរាយការណ៍ថា ទំហំផ្ទៃដីស្រោចស្រព ធៀបនឹងផ្ទៃដីដាំដុះសរុបនៅកម្ពុជា មានត្រឹមតែ ២០% ប៉ុណ្ណោះ។

ដោយមានការគាំទ្រហិរញ្ញវត្ថុពី AusAID សមាសភាគសេដ្ឋកិច្ចនៃ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក (WRMRCDP)[2] មានគោលដៅដោះស្រាយបញ្ហាសំខាន់ៗបី៖ (១) ផលិតភាពទឹក (២) ឥទ្ធិពលនៃចំណាកស្រុក សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងឧបសគ្គខាងឥណទាន ទៅលើការពង្រឹងវិស័យកសិកម្ម និង (៣) ផលប៉ះពាល់នៃប្រព័ន្ធធារាសាស្រ្ត ទៅលើស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចគ្រួសារ។

ការសិក្សានេះ ផ្តោតទៅលើបញ្ហាទី៣ ដោយពិនិត្យពីទំនាក់ទំនងរវាង ប្រព័ន្ធធារាសាស្រ្ត និងចំនួនទ្រព្យសម្បត្តិគ្រួសារ ដូចជា ទ្រព្យប្រើយូរឆ្នាំ សត្វចិញ្ចឹម បរិក្ខារកសិកម្ម គោក្របី និងសត្វអូសទាញ។ អត្ថបទនេះរួមមាន៖ ផ្នែកទី២ ដែលពិនិត្យពីការសិក្សាមានស្រាប់ ផ្នែកទី៣ ពិពណ៌នាពីលក្ខណៈនៃទិន្នន័យប្រមូលបាន ផ្នែកទី៤ ពិភាក្សាពីវិធីសាស្រ្តបានប្រើប្រាស់ជាក់ស្តែង និងបង្ហាញពីលទ្ធផលរកឃើញ និង ផ្នែកទី៥ បូកសរុបពីការសិក្សា។

[2] WRMRCDP មានសមាសភាគបី គឺសមាសភាគ រូបវន្ត អភិបាលកិច្ច និងសេដ្ឋកិច្ច (CDRI 2010)។

# ២ ការសិក្សាឯកសារមានស្រាប់

នៅឆ្នាំ២០០៥ ដីកសិកម្មទទួលបានការស្រោចស្រពនៅកម្ពុជា មានត្រឹម ១៩,៦% នៃផ្ទៃដីដាំដុះសរុប (FAO 2005)។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃការអភិវឌ្ឍវិស័យទឹក ដើម្បីសម្រេចគោលដៅដ៏ធំទូលាយនៃ ការអភិវឌ្ឍជនបទនិងកសិកម្ម កំណើនសេដ្ឋកិច្ច ការបង្កើតការងារនិងបង្កើនប្រាក់បៀវត្សរ៍ និងសុខុមាលភាពសេដ្ឋកិច្ច-សង្គមកិច្ចជាទូទៅ រាជរដ្ឋាភិបាលបាននិងកំពុងជំរុញការស្តារ និងស្ថាបនាប្រព័ន្ធធារាសាស្ត្រនៅទូទាំងប្រទេស។

គេតែងជឿថា ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រជាកតាលីករគន្លឹះដែលជំរុញកំណើនជារួមក្នុងវិស័យកសិកម្ម ប៉ុន្តែនៅមិនទាន់មានការធ្វើការសិក្សា ឲ្យបានទូលំទូលាយនៅឡើយទេ ដើម្បីដឹងថា តើគំនិតនេះវាត្រឹមត្រូវប៉ុណ្ណានោះ។ Wokker *et al.* (ជិតចេញផ្សាយ) បានប្រើប្រាស់ទិន្នន័យពីរផ្សេងគ្នាដែលប្រមូលបានបន្តបន្ទាប់ ដោយវិទ្យាស្ថាន CDRI ក្នុងឆ្នាំ២០០៨-២០០៩ ដើម្បីប៉ាន់ស្មានពីទំនាក់ទំនងរវាង ផលិតភាពស្រូវ និង ភាពមានទឹកប្រើប្រាស់នៅតាមក្បាលដី។ ដោយគិតបញ្ចូលគ្រប់ប្រភេទទាំង កសិករ និងដីដាំដុះ ព្រមទាំងការជ្រើសរើសធ្វើការស្រោចស្រពបំពេញបន្ថែមដោយខ្លួនឯងនោះ អ្នកនិពន្ធបានរកឃើញថា ចំណូលឯកតាបន្ថែម (marginal return) ដែលកសិករទទួលបានពីប្រព័ន្ធធារាសាស្ត្រ មានកម្រិតទាបជាខ្លាំងក្នុងរដូវវស្សា និងកើនឡើងខ្ពស់ក្នុងរដូវប្រាំង ទោះបីជាហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រដែលអាចប្រើបានក្នុងរដូវប្រាំងនៅមានតិចក្តី។

ការសិក្សាដោយ Wokker *et al.* (ibid.) បានបង្ហាញពី ចំណូលឯកតាបន្ថែមតាមរដូវ នៃហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ប៉ុន្តែបើពិនិត្យតាមសូចនាករនៃការបង្កើនទ្រព្យកសិកម្ម គេមិនទាន់ដឹងច្បាស់ទេថា តើហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រនៅកម្ពុជា បានជួយកែលំអជីវភាពរស់នៅរបស់អ្នកក្រ ឬយ៉ាងណានោះទេ។ ការសិក្សាសេដ្ឋមាត្រ (econometric studies) ថ្មីៗពីប្រទេសផ្សេងៗ បានបង្ហាញច្បាស់ថា ប្រព័ន្ធធារាសាស្ត្រ ជួយផ្លាស់ប្តូរលំនាំដាំដុះ ដោយបង្កើនដំណាំលក់យកប្រាក់មានតម្លៃខ្ពស់ បង្កើនផលិតកម្មដំណាំ បង្កើនបរិក្ខារកសិកម្មនិងទ្រព្យប្រើយូរឆ្នាំ និងមានផលប៉ះពាល់វិជ្ជមានដល់ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច ដូចជា ប្រាក់ចំណូល អាហារូបត្ថម្ភនិងសុខភាព តាមការកាត់បន្ថយវិសមភាព និងភាពក្រីក្រ[3]។ ជាឧទាហរណ៍ Dillon (2011) បានប្រើប្រាស់ទិន្នន័យបានពីអង្កេតទៅលើ ២៤៥គ្រួសារ នៅប្រទេសម៉ាលីភាគខាងជើង ក្នុងឆ្នាំ១៩៩៧-១៩៩៨ និង ២០០៦ ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃប្រព័ន្ធធារាសាស្ត្រខ្នាតតូច ទៅលើចំណាយប្រើប្រាស់ ទ្រព្យសម្បត្តិ និងការធានារ៉ាប់រងក្រៅផ្លូវការរបស់គ្រួសារ។ ដោយប្រើវិធីសាស្ត្រ propensity score matching និង difference-in-difference matching ដើម្បីកែតម្រូវលំអៀងក្នុងការជ្រើសរើសនោះ Dillon (ibid.) បានរកឃើញថា ប្រព័ន្ធធារាសាស្ត្រជួយបង្កើនចំណាយប្រើប្រាស់ផលិតកម្មកសិកម្ម និងសត្វចិញ្ចឹមរបស់គ្រួសារ ហើយកាត់បន្ថយហានិភ័យ និងពង្រឹងបណ្តាញចែកចាយអាហារក្រៅផ្លូវការឲ្យគ្នា។ ការសិក្សាទាំងនេះបានគាំទ្រដល់ការស្រាវជ្រាវជាលក្ខណៈទ្រឹស្តី និងសំអាងលើបទពិសោធន៍កន្លងមក ស្តីពីផលប៉ះពាល់នៃប្រព័ន្ធធារាសាស្ត្រទៅលើផលិតកម្ម និងការប្រើប្រាស់ (e.g. Hussain & Hanjra 2004)។

Huang *et al.* (2006) បានប្រើទិន្នន័យថ្នាក់ជាតិ សរុប ១១៩៩គ្រួសារ ក្នុង ៦០ភូមិ នៅប្រាំមួយខេត្តក្នុងតំបន់ជនបទប្រទេសចិន ដើម្បីកំណត់ពីឥទ្ធិពលប្រព័ន្ធធារាសាស្ត្រ ទៅលើទិន្នផល និងប្រាក់ចំណូលពីដំណាំ ព្រមទាំងប្រាក់ចំណូលផ្សេងៗ ក្នុងតំបន់ក្រីក្រ។ ការប៉ាន់ស្មានដោយប្រើវិធីសាស្ត្រ multivariate regression បង្ហាញថា ប្រព័ន្ធធារាសាស្ត្រ បានរួមចំណែកជួយបង្កើនទិន្នផលស្ទើរគ្រប់មុខដំណាំ និងប្រាក់ចំណូលរបស់កសិករនៅគ្រប់

[3] សូមមើល Hanji (2006) និង Hussain (2007a, 2007b) ដើម្បីបានព័ត៌មានលំអិតលើការសិក្សាពីមុនៗ ស្តីពី ផលប៉ះពាល់នៃប្រព័ន្ធធារាសាស្ត្រ ទៅលើលំនាំនៃការដាំដុះ ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច ការបង្កើនទ្រព្យសម្បត្តិ និងគុណភាពជីវិត ព្រមទាំងផលប៉ះពាល់នៃពាណិជ្ជកម្ម ទៅលើចំណាយលើស្បៀងអាហារ អាហារូបត្ថម្ភ និងសុខភាព ក៏ដូចជាស្ថានភាពអាហារូបត្ថម្ភរបស់ក្មេងស្រីជំទង់។